# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម


## គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយតាតរៈបរិស្ថាន

**Climate-Friendly Agribusiness Value Chains Sector Project (CFAVC)**

**ADB Loan No. 3661-CAM (COL), 8346-CAM (EF) and Grant No. 0579 (EF)**

# ឯកសារមេរៀនបណ្តុះបណ្តាល ស្តីពី
# មូលដ្ឋានគ្រឹះទីផ្សារសម្រាប់សហគមន៍កសិកម្ម

## MARKETING PRINCIPLES FOR AGRICULTURAL COOPERATIVES





រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (DACP)

ឆ្នាំ ២០២១

# តារាងមាតិកា

**១. សេចក្តីផ្តើម** ......... 3
**១.១- និយមន័យទីផ្សារ** ......... 3
**១.២- ប្រភេទនៃសេដ្ឋកិច្ច** ......... 3
**២- មូលដ្ឋានគ្រឹះនៃទីផ្សារ** ......... 5
**២.១- ផលិតផលកសិកម្ម** ( Production ) ......... 5
២.១.១. បង្កើតផែនការផលិត និងផែនការទីផ្សារ ......... 6
២.១.២. ការផ្គត់ផ្គង់ និងតម្រូវការ ......... 8
២.១.៣. វដ្តជីវិតផលិតផល (Product Life Cycle) ......... 9
**២.២- ការកំណត់តម្លៃ** ( Price ) ......... 11
២.២.១. ការប៉ាន់ស្មានការផលិត និងការលក់ប្រចាំខែ ......... 11
២.២.២. កត្តាដែលនាំឥទ្ធិពលដល់តម្លៃ ......... 12
២.២.៣. ប្រភពព័ត៌មានក្នុងការកំណត់ថ្លៃ ......... 12
២.២.៤. ចំណាយនៅក្នុងសហគមន៍កសិកម្ម ......... 13
២.២.៥. អតិថិជន និងគូប្រកួតប្រជែង ......... 15
**២.៣- ទីតាំងបណ្តាញចែកចាយ** ( Place ) ......... 15
**២.៤- ការផ្សព្វផ្សាយ** ( Promotion ) ......... 16
២.៤.១. ការផ្សាយពាណិជ្ជកម្មៈ ......... 16
២.៤.២. យុទ្ធសាស្ត្រលក់ៈ ......... 17
២.៤.៣. ទំនាក់ទំនងជាមួយអតិថិជនៈ ......... 18
**២.៥. ការស្រាវជ្រាវទីផ្សារ** ......... 18
២.៥.១. អតិថិជនគោលដៅ ......... 19
២.៥.២. តម្រូវការ ......... 19
២.៥.៣. តម្លៃ ......... 19

# ១. សេចក្តីផ្តើម

## ១.១- និយមន័យទីផ្សារ

**ផ្សារ (Market)** គឺជាទីកន្លែងជួបគ្នារវាងអ្នកលក់ និងអ្នកទិញ ដើម្បីទិញ លក់ផលិតផល។ ឧទាហរណ៍៖ ផ្សារថ្មី ផ្សារអូឬស្សី ផ្សារអ៊ីអន ផ្សារម៉ាក្រូ។

**ទីផ្សារ (Marketing)** គឺសំដៅទៅលើ កិច្ចការដែលសហគមន៍កសិកម្មត្រូវធ្វើដើម្បីទាក់ទាញអតិថិជនក្នុងការដោះដូរទំនិញ ឬសេវាកម្មរបស់ខ្លួន និងរក្សានូវទំនាក់ទំនងអោយបានយូរអង្វែង។ កិច្ចការទាំងនោះមានដូចជា ការបង្កើតផលិតផល ការកំណត់តម្លៃ ការជ្រើសរើសទីតាំង និងការផ្សាយពាណិជ្ជកម្មជាដើម។




អ្នកអាចចាត់ទុកផលិតផល ឬសេវាកម្មរបស់សហគមន៍កសិកម្ម មានតម្រូវការទីផ្សារបានលុះត្រាតែ៖

- អតិថិជន **ត្រូវការ**នូវផលិតផលរបស់អ្នក
- អតិថិជន**មានលទ្ធភាព** (មានលុយ)ទិញផលិតផលរបស់អ្នក
- អ្នកទិញ**ចង់ទិញ**នូវផលិតផលរបស់អ្នក
- អ្នកអាចលក់ផលិតផល ឬសេវាកម្មបានក្នុងតម្លៃ ដែលទទួលបានប្រាក់ចំណេញសមរម្យ

## ១.២- ប្រភេទនៃសេដ្ឋកិច្ច

ប្រព័ន្ធសេដ្ឋកិច្ចគឺជាប្រព័ន្ធនៃផលិតកម្ម ការលៃលកធនធាន និងការបែងចែកទំនិញឬសេវាកម្មនៅក្នុងសង្គមឬទីតាំងភូមិសាស្រ្តជាក់លាក់ណាមួយ។ វាក៏យោងទៅតាមប្រព័ន្ធនៃសង្គមផងដែរដើម្បីកត់សម្គាល់ទៅលើចំណុចអាទិភាពណាខ្លះដែលសង្គមនៅអាចសម្រេចបានក្នុងគោលបំណងបង្កើតយុទ្ធសាស្រ្តសេដ្ឋកិច្ចដ៏មានប្រសិទ្ធភាព និងទទួលបានភាពជោគជ័យ។ ប្រព័ន្ធនៃសេដ្ឋកិច្ចត្រូវកំណត់ថាអ្វីដែលគេត្រូវផលិតផលិតដោយរបៀបណា និងផលិតទៅឲ្យអ្នកណា។ យ៉ាងណាមិញប្រព័ន្ធនៃសេដ្ឋកិច្ចត្រូវបានគេបែងចែកជា៤បែប៖

**#ទី១ សេដ្ឋកិច្ចបែបប្រពៃណី**

វាគឺជាសេដ្ឋកិច្ចដើមដែលប្រពៃណី ទំនៀមទម្លាប់ និងជំនឿរបស់គ្រួសារ សហគមន៍ ក្រុមកុលសម្ព័ន្ធ ឬសាសនារបស់ខ្លួននឹងកំណត់ពីទំនិញ ឬសេវាកម្មដែលសេដ្ឋកិច្ចនោះត្រូវផលិតនិងចែកចាយហើយភាគច្រើនការដោះដូរទំនិញគឺមិនប្រើប្រាស់លុយកាក់។ ប្រទេសដែលប្រើប្រាស់សេដ្ឋកិច្ចរបៀបនេះភាគច្រើនគឺស្ថិតនៅតំបន់ដាច់ស្រយាលនិងពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង។ គេអាចហៅម្យ៉ាងទៀតថា "ភាពគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិត"។ សេដ្ឋកិច្ចរបៀបនេះគឺមិនសូវមានឬគ្មានការអភិវឌ្ឍន៍ ទទួលយកបច្ចេកវិទ្យា និងផ្អែកសុខាភិបាលពីបរទេសតិចតួច ឬគ្មានសោះដោយប្រពៃណីនឹងសម្រេចពីការចិញ្ចឹមជីវិត ការស្លៀកពាក់ ក៏ដូចជាការតាំងទីលំនៅរបស់ពួកគេដែលប្រព្រឹត្តទៅតាមមនុស្សជំនាន់មុន។ ប៉ុន្តែវាមានលក្ខណៈប្រសើរត្រង់ថាសេដ្ឋកិច្ចបែបនេះនឹងជួយឲ្យប្រជាជននៅតែរក្សាប្រពៃណីទំនៀមទម្លាប់ និងការបំពេញចិត្តមនុស្សជុំវិញបានស្របពេលដែលសេដ្ឋកិច្ចផ្សេងទៀតពិបាកនឹងធ្វើបាន។

#ទី២ សេដ្ឋកិច្ចបញ្ជាឬសេដ្ឋកិច្ចផែនការ

សេដ្ឋកិច្ចរបៀបនេះគឺរដ្ឋមានសិទ្ធិកាន់កាប់ទៅលើសកម្មភាពទាំងស្រុងនៃសេដ្ឋកិច្ចដោយការសម្រេចចិត្តចែកចាយនិងផលិតគឺធ្វើទៅតាមផែនការរបស់រដ្ឋាភិបាល។ វាមិនសូវមានភាពបត់បែនដូចសេដ្ឋកិច្ចទីផ្សារទេហើយប្រតិកម្មផ្លាស់ប្តូរការទិញទំនិញរបស់អ្នកប្រើប្រាស់ និងភាពឡើងចុះនៃការផ្គត់ផ្គង់និងតម្រូវការក៏មានភាពយឺតយ៉ាវផងដែរ។ ឧទាហរណ៍ដូចជាប្រទេសដែលកាន់របបកុម្មុយនីស។ ហេតុផលចម្បងដែលរដ្ឋាភិបាលជ្រើសរើសសេដ្ឋកិច្ចប្រភេទនេះគឺដើម្បីអាចកាន់កាប់ធនធានដែលមានតម្លៃរបស់ខ្លួន (ឧ. ប្រេង រ៉ែមាស)។ រីឯផ្នែកផ្សេងទៀតដូចជាកសិកម្មគឺប្រជាជនជាអ្នកដឹកនាំនិងចាត់ចែង។

#ទី៣ សេដ្ឋកិច្ចទីផ្សារសេរី

រាល់សកម្មភាពនៃការដោះដូរទំនិញដោយសេរី អាស្រ័យទៅលើការត្រូវគ្នារវាងអ្នកប្រើប្រាស់និងអ្នកផ្គត់ផ្គង់។ ក្រុមហ៊ុនក៏ដូចជាស្ថាប័នឯកជនមានសិទ្ធិកាន់កាប់ក្រុមហ៊ុន ដាក់តម្លៃទំនិញ គ្រប់គ្រងសង្វាក់ផលិតកម្ម ក៏ដូចជាបុគ្គលិកដោយខ្លួនឯង។ ចំណែករដ្ឋាភិបាលមិនមានសិទ្ធិគ្រប់គ្រងធនធានចាំបាច់ ទំនិញដែលមានតម្លៃ ឬវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនោះទេ។ ប្រជាជនជាអ្នកកំណត់ថាសេដ្ឋកិច្ចត្រូវប្រព្រឹត្តទៅដោយរបៀបណា ការផ្គត់ផ្គង់ត្រូវធ្វើដូចម្តេច និងតម្រូវការអ្វីខ្លះដែលចាំបាច់។ ជាក់ស្តែងមិនមានសេដ្ឋកិច្ចទីផ្សារសេរីសុទ្ធសាធនៅក្នុងពិភពលោកឡើយ។ រដ្ឋាភិបាលនៅតែមានចំណែកចំពោះសេដ្ឋកិច្ចខ្លះៗដដែល។

#ទី៤ សេដ្ឋកិច្ចចម្រុះ

ជាសេដ្ឋកិច្ចមួយ ដែលរួមបញ្ចូលកិច្ចសហប្រតិបត្តិការរវាងសេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចផែនការជាមួយគ្នា។ ធនធានត្រូវបានគេបែងចែកទៅឲ្យទាំងឯកជន និងរដ្ឋជាអ្នកត្រួតត្រាតាមវិស័យនីមួយៗដែលប្រើប្រាស់គោលការណ៍ល្អបំផុតចំពោះប្រព័ន្ធទាំងពីរ។ ទីផ្សារសេរីគឺមានតិចឬច្រើនជាងរដ្ឋាភិបាលលើកលែងតែវិស័យសំខាន់ៗមួយចំនួនដូចជា វិស័យអប់រំ ថាមពល (ឧ. អគ្គិសនីកម្ពុជា) ទូរគមនាគម៍ជាដើម។ វិស័យទាំងនោះមិនអាចឲ្យឯកជនកាន់កាប់ទាំងស្រុងបានទេព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ។ ជាក់ស្តែងយើងឃើញថាវិស័យផ្សេងៗគឺមានទាំងរដ្ឋនិងឯកជន (ឧ. វិស័យអប់រំ)។ ទោះបីជាតាមទ្រឹស្តីគឺគេចង់ធ្វើយ៉ាងណាឲ្យវិស័យទាំងពីរអាចទាញយកផលប្រយោជន៍ពីគ្នាទៅវិញទៅមកឲ្យបានល្អយ៉ាងណាក៏ដោយ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងគឺមិនងាយនោះឡើយ។ យើងឃើញថាទំហំនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលគឺធំដែលជួនកាលអាចមានឥទ្ធិពលលើសពីភាពចាំបាច់ទៅទៀត។ សម្រាប់សេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាគឺអនុវត្តតាមសេដ្ឋកិច្ចទីផ្សារសេរី។

# ២- មូលដ្ឋានគ្រឹះនៃទីផ្សារ

ទីផ្សារ គឺជាយុទ្ធសាស្ត្រអាជីវកម្មដើម្បីធ្វើឱ្យទំនិញ និងសេវាទាក់ទាញអតិថិជនសក្តានុពល។ ដើម្បីធ្វើអោយទំនិញ ឬសេវាកម្មអាចទាក់ទាញអតិថិជន សហគមន៍កសិកម្មត្រូវអនុវត្តជំហាន០៤ សំខាន់៖

- **ផលិតផល៖** ទំនិញឬសេវាកម្មដែលសហគមន៍កសិកម្មនឹងលក់ឱ្យអតិថិជន
- **តម្លៃ៖** ការកំណត់តម្លៃទំនិញនិងសេវាកម្មរបស់សហគមន៍កសិកម្មសម្រាប់លក់ឱ្យអតិថិជន
- **ទីតាំង៖** របៀបនិងទីកន្លែងដែលសហគមន៍កសិកម្មនឹងនាំផលិតផលឱ្យដល់អតិថិជន
- **ការជំរុញការលក់៖** របៀបដែលសហគមន៍កសិកម្មបង្ហាញអតិថិជនពីផលិតផលឬសេវាកម្មរបស់សហគមន៍កសិកម្ម និងរបៀបដែលសហគមន៍កសិកម្មទាក់ទាញអតិថិជន និងរក្សាអតិថិជន។




## ២.១- ផលិតផលកសិកម្ម ( Production )

ផលិតផលសំដៅទៅដល់ទំនិញ ឬសេវាកម្មមួយឬច្រើន ដែលសហគមន៍កសិកម្មមានផែនការផ្តល់ជូនអតិថិជនគោលដៅរបស់ខ្លួន។ ការកំណត់លក្ខណៈរបស់ផលិតផល គឺធ្វើទៅតាមតម្រូវការរបស់អតិថិជនគោលដៅរបស់យើង។

នៅពេលយើងផលិតផលិតផលមួយ យើងត្រូវគិតទៅលើចំនុចមួយចំនួនដូចជា គុណភាព សុវត្ថិភាព រស់ជាតិ ទំហំ ពណ៌សម្បុរ ភាពស្អាត ភាពស្រស់ ឬប្រភព(អ្នកផលិត)។

តារាងគំរូ១៖ លក្ខណៈផលិតផលរបស់សហគមន៍កសិកម្ម

| | |
|---|---|
| ផលិតផល(ទំនិញ ឬសេវាកម្ម) | ត្រសក់ផ្អែ |
| គុណភាព | សុវត្ថិភាព ស្រស់ៗ |
| រស់ជាតិ | មិនសាប និងស្រួយ |
| ឈ្មោះអ្នកផ្គត់ផ្គង់ (ក្រុមហ៊ុន) | ផលិតដោយកសិករក្នុងស្រុក |
| ពណ៌ | ពណ៌បៃតងស្រស់ |
| ទំហំ | ទំហំតូចៗ ៣សង់ទីម៉ែត្រ គុណ ១០សង់ទីម៉ែត្រ |
| ការវេចខ្ចប់ | មួយកញ្ចប់ ២០០ក្រាម ៥០០ ក្រាម |
| លក្ខណៈប្លែករបស់ផលិតផលធៀបនឹងគូប្រកួតប្រជែង | វេចជាកញ្ចប់តូចៗ ផ្លែមានទំហំប៉ុនៗគ្នា |

តារាងគំរូ២៖ លក្ខណៈផលិតផលរបស់សហគមន៍កសិកម្ម

| | |
|---|---|
| ផលិតផល(ទំនិញ ឬសេវាកម្ម) | ជីគីមី (NPK១៥-១៥-១៥ UREA) |
| គុណភាព | ភាពសុទ្ធពីរោងចក្រ |
| ឈ្មោះអ្នកផ្គត់ផ្គង់(ក្រុមហ៊ុន) | ក្រុមហ៊ុនកសិកររុងរឿង |
| ពណ៌ | ក្រម៉ៅខ្លាំង |
| ទំហំ(ស៊េរី) | |
| ការវេចខ្ចប់ | ២៥ គីឡូក្រាម ៥០ គីឡូក្រាម |
| លក្ខណៈប្លែករបស់ផលិតផលធៀបនឹងគូប្រកួតប្រជែង | ជាកញ្ចប់តូចៗ សុទ្ធល្អ(មិនដូរសម្បកវេចខ្ចប់) |

## ២.១.១. បង្កើតផែនការផលិត និងផែនការទីផ្សារ

ផែនការដាំដុះតាមរដូវកាលបានផ្សារភ្ជាប់យ៉ាងសំខាន់រវាងផលិតផល (កសិផល) និងតំលៃនៅលើទីផ្សារ។ កសិករគួស្វែងយល់ពីប្រភេទមុខដំណាំ ដែលមានតម្រូវការខ្ពស់លើទីផ្សារ ផែនការដាំដុះ និងប្រមូលផល។ អនុវត្តន៍តាមផែនការនេះ អ្នកនឹងអាចបំពេញតម្រូវការអ្នកប្រើប្រាស់ ដែលប្រការនេះ កសិករអាចទទួលបានប្រាក់ចំណូលខ្ពស់ និងរក្សាបានគុណភាពផលិតផល។

# តារាងកាលវិភាគការដាំដុះតាមរដូវកាល

| ដំណាំ/សត្វ | តារាងកាលវិភាគការដាំដុះតាមរដូវកាល | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ស្រូវវស្សា | | | | | | | | | | | | |
| ស្រូវប្រាំង | | | | | | | | | | | | |
| ត្រសក់ | | | | | | | | | | | | |
| ប៉េងប៉ោះ | | | | | | | | | | | | |
| មាន់ | | | | | | | | | | | | |
| ត្រី | | | | | | | | | | | | |









### ២.១.២. ការផ្គត់ផ្គង់ និងតម្រូវការ

ហេតុអ្វីបានជាមានការប្រែប្រួលតំលៃនៅលើទីផ្សារ? ការប្រែប្រួលតំលៃគឺអាស្រ័យលើទំហំនៃតម្រូវការ និងការផ្គត់ផ្គង់ ពោលគឺៈ

- បើមានតំរូវការច្រើន តែមានការផ្គត់ផ្គង់តិច នាំឲ្យតំលៃឡើងខ្ពស់
- បើមានតំរូវការតិច តែមានការផ្គត់ផ្គង់ច្រើន នាំឲ្យតំលៃចុះទាប

តារាងការវិភាគតម្រូវការ និងការផ្គត់ផ្គង់បន្លែត្រសក់








## ២.១.៣. វដ្តជីវិតផលិតផល (Product Life Cycle)




- **ដំណាក់កាលកកើត៖** ដំណាក់កាលនេះត្រូវចំណាយពេលច្រើនក្នុងការផ្សព្វផ្សាយ និងឲ្យអតិថិជនសាកល្បងផលិតផល ដែលផលចំណេញពេលដំបូងមិនទាន់កើតមានឡើងទេ និងពេលខ្លះអាចខាតបង់ទៀតផង
- **ដំណាក់កាលរីកចម្រើន៖** ប្រសិនបើផលិតផលរបស់អ្នកមានភាពទាក់ទាញ និងឆ្លើយតបគ្រប់គ្រាន់ចំពោះអតិថិជន វានឹងឈានដល់ដំណាក់កាលកើនឡើងយ៉ាងឆាប់រហ័ស និងបង្ហាញពីផលចំណេញ

- **ដំណាក់កាលទ្រឹង៖** ដំណាក់កាលនេះ បរិមាណការលក់មានល្បឿនយឺត ផលិតផលទទួលបានប្រាក់ចំណេញខ្ពស់ ប៉ុន្តែដោយមានការកើនឡើងនៃដៃគូតប្រកួតប្រជែង បានដឹកនាំឲ្យមានការថយចុះ ហើយប្រាក់ចំណេញក៏ថយចុះ
- **ដំណាក់ឌីនភាព៖** បរិមាណនៃការលក់ និងប្រាក់ចំណេញមានការធ្លាក់ចុះ

តារាងការវិភាគផលិតផល៖

| ផលិតផល | ផលិតផលរបស់ខ្ញុំ | ផលិតផលរបស់គូប្រកួតប្រជែង |
|---|---|---|
| ១. ចំនួនផលិតផល  | | |
| ២. លក្ខណៈសម្បត្តិផលិតផល  | | |
| ៣. ការវេចខ្ចប់ផលិតផល  | | |
| ៤. ស្លាកសញ្ញា/យីហោ | | |
| ៥. សេវាកម្មអតិថិជន  | | |
| ៦. វត្ថុធាតុដើម/បច្ចេកទេសផលិត | | |
| ៧. ម៉ូដនិងភាពងាយស្រួលប្រើ | | |
| ៨. គិតពីគុណតម្លៃអ្នកទិញ | | |
| ៩. អាកប្បកិរិយាអ្នកលក់ | | |
| តើចំណុចណាខ្លះ ដែលខ្ញុំគួរផ្លាស់ប្តូរ ដើម្បីអោយផលិតផលរបស់ខ្ញុំខុសពីគេ? | | |

## ២.២- ការកំណត់តម្លៃ ( Price )

តម្លៃគឺជាចំនួនទឹកប្រាក់ដែលអតិថិជនគោលដៅរបស់សហគមន៍កសិកម្ម មានលទ្ធភាពបង់មកអោយសហគមន៍កសិកម្មនៅពេលដែលគេមានបំណងទិញ ឬប្រើសេវាកម្មរបស់សហគមន៍កសិ កម្ម។ ដើម្បីកំណត់តម្លៃសហគមន៍កសិកម្មត្រូវ៖

- ដឹងពីចំណាយរបស់សហគមន៍កសិកម្ម
- ដឹងពីតម្លៃសមស្របសម្រាប់អតិថិជនសក្តានុពល
- ដឹងពីតម្លៃរបស់គូប្រកួតប្រជែង

### ២.២.១. ការប៉ាន់ស្មានការផលិត និងការលក់ប្រចាំខែ

តម្លៃរបស់ផលិតផល ពាក់ព័ន្ធយ៉ាងសំខាន់ជាមួយបរិមាណនៃការលក់របស់យើង។ ដូចនេះសហគមន៍កសិកម្ម ត្រូវធ្វើការប្រាន់ស្មានការលក់ប្រចាំខែ ដើម្បីកំណត់ថ្លៃដើមរបស់ផលិតផល។ ដើម្បីធ្វើការប៉ាន់ស្មានការលក់ប្រចាំខែ យើងត្រូវដឹងពីតម្រូវការ និងសមត្ថភាពផលិតរបស់យើង៖

តារាងគំរូ៖ ផែនការប៉ាន់ស្មានតម្រូវការសេវាកម្មត្រាក់ទ័ររបស់សមាជិកសហគមន៍កសិកម្ម

| ផលិតផល (ទំនិញឬសេវាកម្ម) | | ការផ្តល់សេវាកម្មប្រចាំខែ | | | | | | សរុប | មធ្យម |
|---|---|---|---|---|---|---|---|---|---|
| | | ៥ | ៦ | ៧ | ៨ | ៩ | ១០ | | |
| ភ្ជួរ | ហិចតា | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ | ១០៨០ | ១៨០ |

តារាងគំរូ៖ លទ្ធភាពក្នុងការផ្តល់សេវាកម្មត្រាក់ទ័ររបស់សហគមន៍កសិកម្មដើម្បីកសិករ

| ផលិតផល (ទំនិញឬសេវាកម្ម) | | ការផ្តល់សេវាកម្មប្រចាំខែ | | | | | | សរុប | មធ្យម |
|---|---|---|---|---|---|---|---|---|---|
| | | ៥ | ៦ | ៧ | ៨ | ៩ | ១០ | | |
| ភ្ជួរ | ហិចតា | ៩០ | ៩០ | ៩០ | ៩០ | ៩០ | ៩០ | ៥៤០ | ៩០ |

ដើម្បីគណនាពេលវេលាដែលខកខានមិនបានផ្តល់សេវាកម្មដោយកត្តាផ្សេងៗ គួត្រូវបន្ថយ ១0% និងអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង។

តារាងគំរូ៖ ការប៉ាន់ស្មានការផ្តល់សេវាកម្មត្រាក់ទ័ររបស់សហគមន៍កសិកម្មដើម្បីកសិករ

| ផលិតផល (ទំនិញឬសេវាកម្ម) | | ការផ្តល់សេវាកម្មប្រចាំខែ(ក្រោយបន្ថយ១០%) | | | | | | សរុប | មធ្យម |
|---|---|---|---|---|---|---|---|---|---|
| | | ៥ | ៦ | ៧ | ៨ | ៩ | ១០ | | |
| ភ្ជួរ | ហិចតា | ៨១ | ៨១ | ៨១ | ៨១ | ៨១ | ៨១ | ៤៨៦ | ៨១ |

### ២.២.២. កត្តាដែលនាំឥទ្ធិពលដល់តម្លៃ

- **កត្តាសេដ្ឋកិច្ច៖** សភាពការបច្ចុប្បន្ន និងអនាគតនៃសេដ្ឋកិច្ចជាញឹកញយ ជាកត្តាគន្លឹះក្នុងការកំណត់កំរិតតម្លៃ។
- **កត្តាផ្គត់ផ្គង់ និងតម្រូវការ៖** តម្លៃចុះទាប នៅពេលដែលបរិមាណនៃការផ្គត់ផ្គង់ លើសពីតម្រូវការ។
- **ការប្រកួតប្រជែង៖** សហគមន៍កសិកម្ម ឬក្រុមហ៊ុនមួយអាចកំណត់តម្លៃដោយខ្លួនឯងដើម្បីអាចប្រកួតប្រជែង នៅក្នុងទីផ្សារមួយបាន។




### ២.២.៣. ប្រភពព័ត៌មានក្នុងការកំណត់ថ្លៃ

ព័ត៌មានចូលរួមយ៉ាងសំខាន់មិនត្រឹមតែនៅក្នុងជីវិតប្រចាំថ្ងៃនោះទេ ប៉ុន្តែវាក៏មាននាទីយ៉ាងសំខាន់ក្នុងដំណើរការប្រព័ន្ធទីផ្សារ។ ព័ត៌មានទីផ្សារកសិកម្ម គឺដើម្បីពង្រឹងសមត្ថភាពរបស់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ ក្នុងវិស័យកសិកម្ម ដើម្បីទទួលយក ប្រមូលផ្តុំ វិភាគ និងប្រើប្រាស់ព័ត៌មាន ដើម្បីឆ្លើយតបបានកាន់តែប្រសើរទៅនឹងតម្រូវការទីផ្សារ។

**អត្ថប្រយោជន៍ព័ត៌មានទីផ្សារ៖**

- បង្កើនប្រសិទ្ធភាពក្នុងការទទួលបាននូវព័ត៌មានទីផ្សារកសិកម្មសម្រាប់កសិករ ពាណិជ្ជករ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងសង្វាក់ទីផ្សារកសិកម្ម ដើម្បីជួយពួកគាត់អោយលក់បានក្នុងតម្លៃល្អមួយ និងបង្កើតបណ្តាញទំនាក់ទំនងទីផ្សារកសិកម្ម ដើម្បីជាប្រយោជន៍ដល់ពួកគាត់
- ធ្វើឲ្យកសិករមានជម្រើសកាន់តែច្រើនឡើង ក្នុងការធ្វើទីផ្សារផលិតផលរបស់ពួកគាត់ ជាមួយនឹងការចរចាតម្លៃមួយ ប្រសើរជាងមុននៅក្នុងសង្វាក់ទីផ្សារកសិកម្ម
- ធ្វើឲ្យកសិករ និងពាណិជ្ជករមានសមត្ថភាពកាន់តែច្រើនជាងមុន ក្នុងបច្ចេកទេសមុន និងក្រោយប្រមូលផល ជាពិសេសការធ្វើចំណាត់ថ្នាក់ផលិតផល ការវេចខ្ចប់ ការរក្សាទុក និងបច្ចេកទេសក្នុងការដឹកជញ្ជូន ដើម្បីធ្វើឲ្យផលិតផលរបស់ពួកគាត់ទទួលបានតម្លៃកាន់តែប្រសើរឡើង។ ខាងក្រោមគឺជាឧទាហរណ៍ប្រភពព័ត៌មានទីផ្សារ៖

https://amis.org.kh/
សេវាពត៌មានទីផ្សារប្រចាំថ្ងៃ

Tolesap App
បច្ចេកទេសដាំដុះ ចិញ្ចឹម និងពត៌មានទីផ្សារទផ្សារ

### ២.២.៤. ចំណាយនៅក្នុងសហគមន៍កសិកម្ម

អាជីវកម្មមួយមានប្រភេទចំណាយផ្សេងៗគ្នាជាច្រើនដែលអាចបែងចែកជាពីរប្រភេទ៖

ក. <u>ចំណាយអថេរ</u> (ចំណាយប្រែប្រួល)

ចំណាយនេះផ្លាស់ប្តូរទៅតាមបរិមាណទំនិញ ឬសេវាដែលបានផលិតឬផ្តល់ ជាធម្មតាត្រូវបានផ្តោតទៅលើវត្ថុធាតុដើម ឬកម្លាំងពលកម្ម។

- **វត្ថុធាតុដើម**

វត្ថុធាតុសំខាន់ៗសម្រាប់ធ្វើជាផលិតផលសម្រេចចុងក្រោយ ឬផ្តល់សេវាកម្ម ។ ឧទាហរណ៍៖ ការចំណាយផ្សេងៗក្នុងដំណើរការហាងកាត់សក់រួមមាន សាប៊ូ និងជេលលាបសក់ ឬទឹក និងភ្លើង។ ទាំងនេះជាចំណាយអថេរ ព្រោះវានឹងផ្លាស់ប្តូរទៅតាមបរិមាណទំនិញ ឬសេវាកម្មដែលត្រូវផលិត។

- **ចំណាយលើកម្លាំងពលកម្ម (មិនមែនប្រាក់ខែ)**

ចំណាយទាំងនេះជាចំនួនប្រាក់ឈ្នួលដែលសហគមន៍កសិកម្មបង់ឱ្យកម្មករ។ ទាំងនេះជាចំណាយអថេរ ព្រោះប្រាក់ដែលសហគមន៍កសិកម្មបើកឱ្យកម្មករ ប្រែប្រួលទៅតាមបរិមាណទំនិញ ឬសេវាកម្មដែលបានផលិត ឬផ្តល់អោយអតិថិជន។

តារាងគំរូៈចំណាយអថេររបស់សហគមន៍កសិកម្មសម្រាប់មួយហិកតា

| **ចំណាយអថេរ លើសេវាកម្មភ្ជួរក្នុងមួយហិចតា** | | | |
|---|---|---|---|
| បរិយាយ | បរិមាណត្រូវការ | តម្លៃឯកតា | ចំណាយ |
| ប្រេងម៉ាស៊ូត | ១០ លីត្រ | ២,៧០០៛ | ២៧,០០០៛ |
| ប្រេងម៉ាស៊ីន តម្រងប្រេង | | | ៦,០០០៛ |
| កម្មករ | ២ នាក់ | ១០,០០០៛ | ២០,០០០៛ |
| ចំណាយសរុបក្នុងមួយឯកតា | | | ៥៣,០០០៛ |

ខ. ចំណាយថេរ (ចំណាយមិនប្រែប្រួល)

ចំណាយថេរ គឺជាការចំណាយដែលនៅហ្នឹង ដោយមិនប្រែប្រួលអាស្រ័យលើបរិមាណទំនិញ ឬសេវាកម្ម ដែលបានផលិត ឬផ្តល់ហើយជាធម្មតាផ្តោតលើ ប្រាក់ខែ ទីតាំង និងគ្រឿងបរិក្ខារ។

តារាងគំរូ៖ ចំណាយថេរលើកម្លាំងពលកម្មរបស់សហគមន៍កសិកម្ម

| មុខតំណែង | ចំនួន | តម្លៃឯកតា | សរុប |
|---|---|---|---|
| មេកា | ១ | ៤០០,០០០៛/ខែ | ៤០០,០០០៛ |
| អ្នកដឹកប្រេង | ១ | ១២០,០០០៛/ខែ | ១២០,០០០៛ |
| ចំណាយសរុប/ខែ | | | ៥២០,០០០៛ |
| ចំណាយ/ហិចតា | ចំណាយសរុបប្រចាំខែ/បរិមាណលក់ប្រចាំខែ | | ៦,៥០០៛ |

តារាងគំរូ៖ ចំណាយថេរប្រចាំខែរបស់សហគមន៍កសិកម្ម

| មុខទំនិញ | តម្លៃទិញ | អាយុកាលប្រើប្រាស់(ខែ) | ចំណាយ/ខែ |
|---|---|---|---|
| រំលស់ត្រាក់ទ័រ | ១២,០០០,០០០៛ | ៦០ខែ | ២០០,០០០៛ |
| រំលស់រោង | ២,៤០០,០០០៛ | ៦០ខែ | ៤០,០០០៛ |
| ថ្លៃជួសជុល | | | ៤០០,០០០៛ |
| ការដឹកជញ្ជូន/ខែ | | | ៤០០,០០០៛ |
| ចំណាយសរុប/ខែ | | | ១,០៤០,០០០៛ |
| ចំណាយ/ហិចតា | ចំណាយសរុបប្រចាំខែ/បរិមាណលក់ប្រចាំខែ | | ១២,៨០០៛ |

តារាងការគណនាចំណាយសរុប ក្នុងមួយឯកតា (ហិកតា)

| ប្រភេទចំណាយ | ចំណាយក្នុងមួយឯកតា(ហិចតា) |
|---|---|
| ចំណាយអថេរ | ៥៣,០០០៛ |
| ចំណាយថេរលើកម្លាំងពលកម្ម | ៦,៥០០៛ |
| ចំណាយថេរផ្សេងៗ | ១២,៨០០៛ |
| ចំណាយសរុប ក្នុងមួយហិចតា | ៧២,៣០០៛ |

### ២.២.៥. អតិថិជន និងគូប្រកួតប្រជែង

ដើម្បីអាចដឹងពីតម្លៃសមស្របសម្រាប់អតិថិជន និងគូប្រកួតប្រជែង យើងត្រូវធ្វើអង្កេត ដោយផ្ទាល់ទៅលើអតិថិជន និងគូប្រកួតប្រជែង ដោយប្រើប្រាស់តារាង សាមញ្ញដូចខាងក្រោម៖

តារាងទី៖ ការអង្កេតតម្លៃ របស់ផលិតផលនៅលើទីផ្សារ

| ឈ្មោះផលិតផល៖..............................................ទីកន្លែ (ផ្សារ)៖.................................. | | | | | |
|---|---|---|---|---|---|
| ឈ្មោះផលិតផល | តម្លៃ១ | តម្លៃ២ | តម្លៃ៣ | តម្លៃ៤ | តម្លៃមធ្យម |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

តារាងគំរូ៖ ការស្រាវជ្រាវការកំណត់ថ្លៃសេវាកម្មត្រាក់ទ័ររបស់សហគមន៍កសិកម្មដើម្បីកសិករ

| ប្រភេទផលិតផល (ទំនិញឬសេវាកម្ម) | តម្លៃមធ្យមក្នុងទីផ្សារ | តម្លៃខ្ពស់បំផុត | តម្លៃទាបបំផុត | តម្លៃរបស់ខ្ញុំ |
|---|---|---|---|---|
| សេវាកម្មភ្ជួរ | ១០០,០០០រ/ហិចតា | ១១០,០០០ឬ/ហិចតា | ៩០,០០០រ/ហិចតា | ១០០,០០០រ/ហិចតា |

## ២.៣- ទីតាំងបណ្តាញចែកចាយ ( Place )

ទីតាំងសំដៅទៅដល់ដំណើរការនាំយកផលិតផល ឬសេវាកម្ម របស់សហគមន៍កសិកម្មទៅដល់អតិថិជន។ ទីតាំងគឺជាកន្លែងណាក៏ដោយដែលអតិថិជនគោលដៅរបស់យើង អាចរកទិញផលិតផល ឬប្រើប្រាស់សេវាកម្ម របស់យើងបាន វាអាចជា ៖

- ក្នុងផ្ទះ៖ ទីកន្លែងដែលរួមបញ្ចូលរវាងការរស់នៅនិងកន្លែងលក់ដូរ
- ការិយាល័យ៖ ទីកន្លែងដែលរួមបញ្ចូលរវាងកន្លែងលក់ដូរ និងការងារ
- លក់រាយ ឬលក់ដុំ៖ ទីតាំងអចល័តដែលរៀបចំឡើងសម្រាប់ដំណើរការអាជីវកម្ម ដូចជាអគារ ការិយាល័យ ផ្សារទំនើប តូប ឬឃ្លាំង។

- ចល័តៈ ប្រសិនបើសហគមន៍កសិកម្មមានផលិតផល ឬសេវាដែលសហគមន៍កសិកម្មត្រូវបញ្ជូនឱ្យអតិថិជន ទីតាំងល្អបំផុតអាចជារទេះ ម៉ូតូកង់បី ឬថយន្តដឹក។
- ឧស្សាហកម្មៈ ប្រសិនបើអាជីវកម្មរបស់សហគមន៍កសិកម្មពាក់ព័ន្ធនឹងការផលិត ឬផលិត កម្មធំៗ អាចត្រូវមានកន្លែងបែងចែកត្រឹមត្រូវសម្រាប់ការរក្សាទុកផលិតផលតាមតម្រូវការជាក់លាក់នៃអាជីវកម្មប្រភេទនេះ។
- ប្រព័ន្ធឌីជីថលៈ កម្មវិធីលើទូរស័ព្ទដៃ ប្រព័ន្ធផ្សព្វផ្សាយសង្គម គេហទំព័រ...។

តារាងគំរូៈ ផែនការទីតាំងសម្រាប់អាជីវកម្មរបស់សហគមន៍កសិកម្ម

| | |
|---|---|
| ទីតាំងអាជីវកម្មៈ | ផ្ទើ តាំងបន្លែ នៅក្នុងផ្សារទំនើប |
| ប្រភេទទីតាំង | តាំងលក់បន្លែ នៅក្នុងផ្សារទំនើប |
| ស្ថានភាព | ជួល |
| | ជាម្ចាស់ |
| | ត្រូវសាងសង់ |
| | ផ្សេងទៀត(សូមបញ្ជាក់) |
| មូលហេតុនៃការជ្រើសរើស | មានទីតាំងល្អ ចំកន្លែងដែលអតិថិជនតែងតែឆ្លងកាត់ |
| គុណសម្បត្តិរបស់ទីតាំង | មិនចាំបាច់ចំណាយទិញដីបន្ថែម មានទីតាំងធំទូលាយ នៅជាមួយកន្លែងធ្វើការរបស់សហគមន៍កសិកម្ម |
| គុណវិប្បត្តិរបស់ទីតាំង | ត្រូវចំណាយថ្លៃសេវា |
| សុវត្ថិភាពកន្លែងធ្វើការ ការគំរាមកំហែង មុខសញ្ញាគ្រោះថ្នាក់ | គ្មានបំពង់ពន្លត់អគ្គីភ័យ នៅដាច់ឆ្ងាយពីភូមិដែលអាចមានអំពើចោរកម្ម |
| តម្លៃ | ១០% នៃតម្លៃលក់ |
| ចំណាយរាប់បញ្ចូល | ទីតាំង និងសេវាលក់ |

## ២.៤- **ការផ្សព្វផ្សាយ** ( Promotion )

### ២.៤.១. ការផ្សាយពាណិជ្ជកម្មៈ

ជាការផ្តល់ព័ត៌មានដល់អតិថិជនដើម្បីឱ្យពួកគេចាប់អារម្មណ៍ទិញផលិតផល ឬសេវាកម្មរបស់សហគមន៍កសិកម្ម។ វាផ្តោតលើលក្ខណៈផលិតផល ដែលខុសប្លែក ឬល្អជាងគូប្រកួតប្រជែង។

យើងអាចធ្វើការផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗដូចខាងក្រោមៈ

- តាមរយៈទូរទស្សន៍
- តាមរយៈវិទ្យុ
- តាមរយៈអ៊ីនធើណេតៈ Facebook Youtube....

- តាមរយៈខិតប័ណ្ណផ្សព្វផ្សាយ
- តាមរយៈផ្ទាំងផ្សាយពាណិជ្ជកម្មតាមទីសាធារណៈ នៅមុខសហគមន៍កសិកម្ម
- ផ្សព្វផ្សាយដោយផ្ទាល់តាមទីប្រជុំជន ពិធីបុណ្យ ឬពិធីជួបជុំផ្សេងៗ
- កម្មវិធីសាកល្បងគុណភាពដោយផ្ទាល់
- និងតាមមធ្យោបាយផ្សេងៗទៀតៗ

### ២.៤.២. យុទ្ធសាស្រ្តលក់៖

ផ្តោតសំខាន់លើអ្វីដែលសហគមន៍កសិកម្មអាចធ្វើបាន ដើម្បីជំរុញអតិថិជនឱ្យទិញផលិត ផល ឬសេវាកម្មរបស់សហគមន៍កសិកម្ម។ វាតែងផ្តោតលើលក្ខណៈផលិតផលដែលខុសប្លែក ឬល្អជាងគូប្រកួតប្រជែង និងការជំរុញអោយអតិថិជនទិញទំនិញកាន់តែច្រើន។

យុទ្ធសាស្រ្តលក់ដែលគេតែងតែអនុវត្តមានដូចជា៖

- ទៅលក់ផ្ទាល់ដល់អតិថិជន
- ចរចារជាមួយអ្នកលក់រាយអោយស្តុកទំនិញរបស់ខ្លួន
- ផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ដល់អ្នកលក់រាយ
- វេចខ្ចប់អោយមានភាពទាក់ទាញ
- សន្សំពិន្ទុទៅលើទំនិញដែលបានទិញ
- ការផ្តល់ជារង្វាន់នៅពេលអតិថិជនទិញផលិតផល
- ផ្តល់ការលើកទឹកចិត្តនៅចុងឆ្នាំ
- លក់បញ្ចុះតម្លៃ
- ផ្តល់ការលើកទឹកចិត្តចំពោះការដាក់តាំងបានល្អនូវទំនិញរបស់ខ្លួន
- បង្កើនភាពជឿទុកចិត្ត(កសាងកេរ្តិ៍ឈ្មោះ ការធ្វើបង្ហាញ បង្ហាញពីរៀបផលិត...

តារាងគំរូ៖ ផែនការជំរុញអាជីវកម្មសម្រាប់សហគមន៍កសិកម្មដើម្បីកសិករ

| ផែនការផ្សាយពាណិជ្ជកម្ម(សេវាកម្មឆ្នាស់ដោយត្រាក់ទ័រ) | | |
|---|---|---|
| វិធីសាស្រ្ត | ព័ត៌មានលម្អិត | រយៈពេលកំណត់ |
| បិទប្រកាសមុខសហគមន៍កសិកម្ម | ដាក់ផ្ទាំងព័ត៌មានស្តីពីសេវាកម្មត្រាកទ័រ និងអត្ថប្រយោជន៍ដែលសហគមន៍កសិកម្មផ្តល់អោយ | អចិន្ត្រៃយ៍ |
| នាមប័ណ្ណ | បង្កើតនាមប័ណ្ណដែលមានឈ្មោះរបស់សហគមន៍កសិកម្ម អាសយដ្ឋានទំនាក់ទំនង សម្រាប់ចែកជូនអតិថិជន នៅពេលពួលគេ | ត្រូវមាននាមប័ណ្ណរហូត |

| | | |
|---|---|---|
| | ចាប់អារម្មណ៍ សេវាកម្មនេះ។ | |
| ព័ត៌មានទំនាក់ទំនងនៅលើត្រាក់ទ័រ | បោះពុម្ពលេខទូរស័ព្ទលើត្រាក់ទ័រ | អចិន្ត្រៃយ៍ |

| យុទ្ធសាស្ត្រលក់ | | |
|---|---|---|
| វិធីសាស្ត្រ | ព័ត៌មានលម្អិត | រយៈពេលកំណត់ |
| ផ្តល់ការលើកទឹកចិត្តនៅចុងឆ្នាំ | សហគមន៍កសិកម្មនឹងដកប្រាក់១០% ពីប្រាក់ចំណេញប្រចាំឆ្នាំពីមុខរបរសេវាកម្មត្រាក់ទ័រ សម្រាប់លើកទឹកចិត្តដល់សមាជិកដែលប្រើប្រាស់សេវាកម្មនេះ ទៅតាមសមមាត្រនៃការប្រើប្រាស់សេវាកម្មនេះ។ | រហូតដល់មានការកែប្រែជាថ្មី |

តារាងគំរូះ ប្រភេទវិធីសាស្ត្រផ្សព្វផ្សាយពាណិជ្ជកម្ម និងយុទ្ធសាស្ត្រលក់

| វិធីសាស្ត្រផ្សាយពាណិជ្ជកម្ម | យុទ្ធសាស្ត្រលក់ |
|---|---|
| • នាមប័ណ្ណ<br>• បិតប្រកាសមុខសហគមន៍កសិកម្ម<br>• ព័ត៌មានទំនាក់ទំនងនៅលើត្រាក់ទ័រ | ផ្តល់ប្រាក់លើកទឹកចិត្តចុងឆ្នាំ |

### ២.៤.៣. ទំនាក់ទំនងជាមួយអតិថិជនះ

ដើម្បីអោយជំរុញការលក់អោយបានច្រើន សហគមន៍កសិកម្មត្រូវតែកសាងទំនាក់ទំនងជាមួយអតិថិជនអោយបានល្អ តាមរយៈចូលរួមនៅក្នុងការសង្គមផ្សេងៗ ដូចជា ចូលរួមកសាងផ្លូវ ជួយឧបត្ថមជនខ្វះខាត ឬរងគ្រោះ ឬកម្មពិធីមនុស្សធម៌ផ្សេងៗ បង្កើតកម្មពិធីជួបជុំជាមួយ ឬថ្លែងអំណាគុណអតិថិជន។

## ២.៥. ការស្រាវជ្រាវទីផ្សារ

ការស្រាវជ្រាវទីផ្សារគឺជាសកម្មភាពដែលសហគមន៍កសិកម្មត្រូវធ្វើដើម្បីកំណត់ អតិថិជនគោលដៅ តម្រូវការ ឬការចង់បានរបស់ពួកគេ និងតម្លៃ ដែលសមស្របសម្រាប់ពួកគេ។ មូលដ្ឋានគ្រឹះទីផ្សារទាំង០៤ខាងលើអាចដំណើរទៅល្អប្រសើគឺអាស្រ័យទៅលើលទ្ធផលនៃការស្រាវជ្រាវទីផ្សារ។ការស្រាវជ្រាវទីផ្សារជាអ្វីដែលអាជីវកម្មជោគជ័យត្រូវអនុវត្តជាប្រចាំ។ តម្រូវការនិងចំណង់ចំណូលចិត្តរបស់អតិថិជនតែងតែផ្លាស់ប្តូរ ហើយគូប្រកួតប្រជែងតែងតែព្យាយាមបំពេញតម្រូវការនោះ។

### ២.៥.១. អតិថិជនគោលដៅ

សំដៅទៅលើក្រុមមនុស្សដែលសហគមន៍កសិកម្មនឹងជ្រើសរើសដើម្បីលក់ផលិតផល ឬផ្តល់សេវាកម្មអោយ។ អតិថិជនគោលដៅមានដូចជា អ្នកធ្វើស្រូវប្រាំង អ្នកដាំបន្លែស្លឹក អ្នកដាំបន្លែ អ្នកមានចំណូលទាប អ្នកមានចំណូលមធ្យម អ្នកហូបអាហារបួស ....។

### ២.៥.២. តម្រូវការ

ក្រុមមនុស្សផ្សេងគ្នា ចំណង់ចំណូលចិត្តផ្សេងគ្នា តម្រូវការផ្សេងគ្នា។ ដូចនេះការដែលយើងដឹងពីតម្រូវការរបស់អតិថិជនគោលដៅមានសារៈសំខាន់ណាស់ សម្រាប់រៀបចំផែនការទីផ្សារអោយបានត្រឹមត្រូវ។

តម្រូវការមានដូចជា ជីគីមី ជីធម្មជាតិ បន្លែសុវត្ថិភាព បន្លែធម្មជាតិ ម្ហូបអាហារថោកៗដែលអាចហូបបានបាយទន់ បាយរឹងត្រូវការតិចៗសោភ័ណភាព រសជាតិផ្អែម រសជាតិជូរអែមដឹកដល់កន្លែងភាពរាក់ទាក់។

### ២.៥.៣. តម្លៃ

យើងត្រូវកំណត់តម្លៃឬផលិតផលិតផល ដែលមានតម្លៃសមស្របទៅតាមអតិថិជនគោលដៅ។
សហគមន៍កសិកម្មអាចធ្វើការស្រាវជ្រាវទីផ្សារតាមលក្ខណៈសាមញ្ញដូចខាងក្រោមៈ

**ក. ពិភាក្សាជាមួយអតិថិជនដែលមានសក្តានុពល**

- តើពួកគេចង់ទិញផលិតផល/សេវាកម្មអ្វី?
- តើលក្ខណៈទំនិញ ឬសេវាកម្មបែបណាដែលគេចង់បាន?
- តើពួកគេយល់យ៉ាងណាចំពោះអាជីវកម្មផ្សេងទៀតដែលបានលក់ផលិតផល និងផ្តល់សេវាកម្មស្រដៀងគ្នានេះ?
- តើតម្លៃប៉ុន្មានដែលពួកគេអាចទិញបាន?

**ខ. សង្កេតមើលអាជីវកម្មរបស់គូប្រកួតប្រជែង**

- តើទំនិញឬសេវារបស់ពួកគេមានគុណភាពល្អឬទេ?
- តើពួកគេកំណត់ថ្លៃប៉ុន្មាន?
- តើអ្វីជាភាពខុសគ្នារវាងអាជីវកម្មដែលជោគជ័យបំផុតនិងមិនសូវជោគជ័យ?
- តើពួកគេទាក់ទាញអតិថិជនដោយរបៀបណា?

**គ. សាកសួរមិត្តភក្តិគ្រួសារ និងសហគមន៍កសិកម្មផ្សេងៗទៀត**

- តើពួកគេយល់យ៉ាងណាពីគំនិតអាជីវកម្មនេះ(របស់សហគមន៍កសិកម្ម)?
- តើផលិតផល និងសេវាកម្មអ្វីដែលគេលក់ដាច់បំផុត?
- តើពួកគេយល់យ៉ាងណាចំពោះផលិតផលរបស់គូប្រកួតប្រជែងរបស់សហគមន៍កសិកម្ម?

| តារាងគំរូ៖ ការស្រាវជ្រាវទីផ្សាររបស់សហគមន៍កសិកម្ម ដើម្បីកសិករ | | | | |
|---|---|---|---|---|
| អតិថិជនសក្តានុពល | ប្រភពព័ត៌មានទីផ្សារ | ទំនិញនិងសេវាដែលមានតម្រូវការ | តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន | ការវិភាគគូប្រកួតប្រជែង |
| សមាជិកសហគមន៍កសិកម្ម | ការអង្កេតគូប្រកួតប្រជែងនិងការពិភាក្សាជាមួយអតិថិជនសក្តានុពល | សេវាកម្មភ្ជួររាស់ដោយត្រាក់ទ័រកង់បួន | ចង់ប្រើប្រាក់ត្រាក់ទ័រធំ ដែលភ្ជួរបានលឿន | មានត្រាក់ទ័រចំនួនពីរដែលកំពុងបំពេញសេវាកម្មនៅក្នុងតំបន់ តែពួកគេគឺជាអ្នកមកពីក្រៅតំបន់ ហើយមិនសូវមានទំនាក់ទំនងជាមួយសមាជិកសហគមន៍កសិកម្ម |
| កសិករដែលមិនមែនជាសមាជិកសហគមន៍កសិកម្ម | ការសង្កេតគូប្រកួតប្រជែង និងការពិភាក្សាជាមួយសហគមន៍កសិកម្មមូលដ្ឋាន | សេវាកម្មភ្ជួររាស់ដោយត្រាក់ទ័រកង់បួន | ចង់បានសេវាកម្មដែលលឿនហើយតម្លៃថោក | ម្ចាស់ត្រាក់ទ័រអាចជួលអ្នកនៅក្នុងតំបន់អោយធ្វើជាអ្នកគ្រប់គ្រង និងស្វែងរកអតិថិជន |

| តារាងគំរូ៖ ព័ត៌មានការស្រាវជ្រាវទីផ្សាររបស់(ឈ្មោះក្រុម)............................................................................................ | | | | |
|---|---|---|---|---|
| អតិថិជនសក្តានុពល | ប្រភពព័ត៌មានទីផ្សារ | ទំនិញនិងសេវាដែលមានតម្រូវការ | តម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន | ការវិភាគគូប្រកួតប្រជែង |
| | | | | |
| | | | | |